បដិវត្តន៍ផ្កាឈូក

The Lotus Revolution

# ប្រទេសកម្ពុជាៈ ដំណើរទៅមុខ នៃបដិវត្តន៍ផ្កាឈូក!

***<u>បងប្អូនរួមជាតិជាទីគោរព!</u>***

លក្ខណគ្រប់បែបយ៉ាងទាំងអស់ សំរាប់បំផ្ទុះ បដិវត្តន៍ផ្កាឈូក នៅកម្ពុជា កើតមានគ្រប់គ្រាន់ព្រមៗគ្នាអស់ហើយ ដូចជា អំពើក្បត់នៃអ្នកដឹកនាំខ្មែរជាង៣៤ឆ្នាំ ការកាត់ដីឱ្យយួន បញ្ហាព្រំដែន អនិតិរដ្ឋ អំពើពុករលួយដែលរីកដុះដាលគ្រប់ទិសទី ការបង្ក្រាបបាតុករដោយកំលាំងអាវុធ ការរឹតបន្តឹងសេរីភាព ការរំលោភសិទ្ធិមនុស្ស ការបណ្តេញ ពលរដ្ឋចេញពីលំនៅឋាន ដោយកំលាំងទាំងកំរោល ការចាប់អ្នកប្រឆាំងនិងបាតុករដាក់ពន្ធនាគារតាមអំពើផ្តាច់ការ តុលាការនិងកងកំលាំងប្រដាប់អាវុធ បំរើរដ្ឋអំណាច ការបោះឆ្នោតដោយបន្លំមបន្លំ ការកាប់បំផ្លាញព្រៃឈើ ការអត់ការងារធ្វើ អ្នករដ្ឋការបើកប្រាក់បៀវត្សរ៍ ដោយ យឺតយ៉ាវរាប់ខែ អយុត្តិធម៌សង្គម ។ល។ បដិវត្ត ន៍នេះ បានត្រូវកុមារានិងកុមារី ជាបុត្រធីតានៃស្ត្រីជាម្តាយនៅដំបន់ បឹងកក់ និង បូរីកីឡា ដោយមាន ពាក់អាវយឺតរូបផ្កាឈូក និង កាន់ផ្កាឈូក នៅដៃ។ គេនាំគ្នាទៅស្រែកទាមទារនៅមុខសភា ខ្មែរ នៅក្នុងតុលាការ តាម ដងវិថី នៅក្នុងវត្តអារាម នៅមុខវាំង្គ នៅមាត់ទន្លេ មុខព្រះអង្គដងកើល ។ល។ បដិវត្តន៍នេះ នឹងបន្ត ដំណើរទៅមុខឥតថយក្រោយទេ តាមរូបភាពថ្មីៗទៀតរហូតដល់បានជោគជ័យជាទីបញ្ចប់។ ប្រជាជាតិខ្មែរទូទាំងពិភពលោក

កំពុងមើលឃើញភាពចាំបាច់និង ភារៈកិច្ចដ៏ធំធេងខ្លាំងក្លាបំផុតក្នុងការធ្វើបដិវត្តន៍នេះ។ គឺមានតែសេចក្ដីក្លាហាននិង ប្រាជ្ញាបារមីនៃ ប្រជាពលរដ្ឋ ទេ ដែលនឹង អាចដឹកនាំបដិវត្តន៍នេះឱ្យទៅដល់ជោគជ័យគបាន។ ក្រុមប្រឹក្សាជាតិអន្តរកាល នៃ បដិវត្តន៍ផ្កាឈូក នឹងនាំមុខបដិវត្តន៍នេះ ឱ្យអស់សមត្ថភាព ហើយនិងរិះរកជាបន្តបន្ទាប់នូវរូបមន្ត បែបបទ និងដំណើការ នៃ បដិវត្តន៍ដើម្បីយកមកអនុវត្តឱ្យបានជោគជ័យ។ យើងសូម រំលឹកឡើងវិញនូវ បញ្ហាប្រឈមមុខធំៗ បី យ៉ាង របស់បដិវត្តន៍ផ្កាឈូក ១/,ដណ្ដើមយក មកវិញឱ្យបាន នូវឯករាជភាព នៃ ប្រទេសកម្ពុជា។ ២/ រំលំរបបផ្តាច់ការបក្សប្រជាជនហ៊ុនសែន។ ៣/ ពេលណាប្រទេសកម្ពុជា បាន ឯករាជ្យឡើងវិញ និង របបផ្តាច់ការដួលរលំ យើងត្រូវតាក់តែងរបបមួយ ឱ្យមានលទ្ធិប្រជាធិបតេយ្យ។

## ក/របបរាជាកុម្មុយនិស្តខ្មែរក្រហម និង ប្រជាពលរដ្ឋ

បំណែកនយោបាយ ២ មាននូវរូបរាងកាន់តែច្បាស់ឡើងៗ ចាប់ពីសម័យបោះឆ្នោតឆ្នាំ១៩៩៣មកៈ

គឺមួយបំណែកនៃ គណបក្សកាន់ អំណាច រួមជាមួយ គណបក្សរណប និង គណបក្សប្រឆាំង ដែលទទួលស្គាល់រដ្ឋអាយ៉ងហើយចូលរួម គ្រប់សម័យបោះ ឆ្នោតទាំងអស់។ និង មួយទៀត គឺបំណែក នៃប្រជាពលរដ្ឋភាគច្រើនដែល អស់ជំនឿស្រឡាញ់ឯករាជ្យ និង កំពុងបះបោរ រួមមាន សមាគម នានាដូចជា សមាគម អ្នកប្រជា ធិបតេយ្យ ចលនា អំណាច ពលរដ្ឋខ្មែរ ខ្មែរម្ចាស់ស្រុក ផ្ទះកវីខ្មែរ បដិវត្តន៍ផ្កាឈូក ,,, ដែល មិនសុខចិត្តទទួលយក អ្វីៗ ដែលរបប ហ៊ុនសែន បង្កើត ឱ្យមានភាពជាក់ស្ដែង មកដល់សព្វថ្ងៃ ហើយសន្មតថាជាព្រេងវាសនាជៀសមិនរួច។ គេខំប្រយុទ្ធដើម្បីបំបាត់និគមកម្មយួននិងយួនូបនីយកម្ម ដើម្បីរំលំ រដ្ឋផ្តាច់ការ បក្សប្រជាជន ហ៊ុនសែន និងដើម្បីកសាង របបសេរីឯករាជ មុននឹង រៀប ចំការ បោះឆ្នោតដោយសេរី មានតំលាភាព តាម លទ្ធិ ប្រជាធិបតេយ្យ។

តើបំណែកនាយបាយណាមួយ ដែល អាចផ្តល់ក្តីសង្ឃឹមឱ្យប្រជាជាតិខ្មែរ?

បំណែកនយោបាយទី១ ពុំអាច សំរេច បាន នូវដំណោះបញ្ហាប្រឈមមុខទាំង៣នេះទេ ពីព្រោះ រដ្ឋប្រជាជនហ៊ុនសែន កាន់ក្តោបក្តាប់ ស្ថាប័ន រដ្ឋទាំងអស់ ដោយកលាំងអាវុធ ហើយ បន្លឹមបន្លំការបោះ ឆ្នោត និង លទ្ធផលតាម រយៈគណៈកម្មការជាតិរៀបចំការបោះឆ្នោត (គជប)។ អ្នកដែលឆ្លៀតទាញយកប្រយោជន៍បានពិតៗនោះ គឺ យួន ចិន បក្សប្រជាជន ហ៊ុនសែន អ្នកដឹកនាំនិងបនបក្សពួកនៃគណបក្សនេះ គ្រួសារស្ដេច និងអ្នកនយោបាយអាម៉ីអាថោង។ នៅសម័យបោះឆ្នោត ឃុំសង្កាត់ថ្ងៃ ៣មិថុនា២០១២ គណបក្សប្រជាជនបានទទួលកៅអីមេឃុំ១៥៩២ (ជាអាសនៈ ៨២៩២ ទល់នឹង ៧៩៩៣អាសនៈនៅ ឆ្នាំ ២០០៧)។ គណបក្សសមរាំងស៊ី បានទទួលកៅអីមេឃុំ២២ (ជាអាសនៈ ២១៥៥ ទល់នឹង ២៦៦០អាសនៈពីឆ្នាំ២០០៧)។ គណបក្ស សិទ្ធិមនុស្ស បានទទួលកៅអីមេឃុំ១៨ (ជាអាសនៈ ៨០០)។ គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលកៅអីមេឃុំ១ (ជាអាសនៈ ១៥១ ទល់នឹង ២៧៤អាសនៈពីឆ្នាំ២០០៧)។ ហើយគណបក្សរ៉ាណារិទ្ធ គ្មានបានទទួលកៅអីមេឃុំទេ(ជាអាសនៈ ៥២ ទល់នឹង ៤២៥អាសនៈពីឆ្នាំ២០០៧)។ កំលាំងប្រឈមមុខ (៤០ ទល់១៥៩២) គ្មានអំណោយផលឱ្យគណបក្សប្រឆាំងទេ។ យោងតាមសង្វាក់នេះ គេត្រូវរង់ចាំការបោះឆ្នោត៤០ដងទៀត ពោលគឺ ២សតវត្សរ៍ ដើម្បីអាចសង្ឃឹមថាមានជ័យជំនះ។ ដូច្នេះ វាហួសពេល សំរាប់ខ្មែរ ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនិគមកម្មយួនបែបនយោបាយ តាមសេដ្ឋកិច្ច និងតាមជនជាតិ។ និយាយឱ្យជ្រៅជ្រះជាងនេះទៀត បើទោះ ជា គណបក្ស ប្រឆាំងឈ្នះ នៅពេលបោះឆ្នោត សភាតំណាងរាស្ត្រនៅថ្ងៃ២៨កក្កដា ឆ្នាំ២០១៣ ក៏គេ គ្មានបំណង ឬក៏គេមិនអាចរំដោះ ឬ ផ្លាស់ប្តូររបប នេះបានដែរ ព្រោះគេទាំងអស់

គ្នាជាអ្នកបង្កើតរបបរាជា កុម្មុយនិស្ត ខ្មែរក្រហម ។ ដោយស្តេចសីហមុនីនៃរបបនេះ បានចុះហត្ថលេខា លើ សន្ធិ សញ្ញា ខ្មែរយួន បំពេញបន្ថែមឆ្នាំ២០០៥ ដូច្នេះ ពលរដ្ឋខ្មែរមើលពុំឃើញសោះថាអ្នកនយោបាយខ្មែរជានិយមកុម្មុយនិស្តនឹងអាចរំដោះប្រទេសកម្ពុជាឱ្យចេញរួចពីក្រញ៉ាំ យួនបានឡើយ ។ ប្រទេសកម្ពុជា ពុំអាចក្លាយទៅជាប្រទេសឯករាជ សេរីនិងប្រកបដោយលទ្ធិប្រជាធិបតេយ្យ តាមផ្លូវនេះបានទេ ។

បំណែកនយោបាយទី២ បដិសេដ្ធមិនទទួល យកវាសនាដែលចារនិងក៏រិត ដោយ អាណានិគមយួន និងអំណាច ផ្តាច់ ការ បក្ស ប្រជា ជនហ៊ុនសែននេះទេ ។ គេលែងមានទំនុកចិត្តលើរបបក្បត់រាជាកុម្មុយនិស្តនេះទៀតហើយ ។ ស្ថានភាពជាក់ ស្តែង បង្ហាញថាយោបល់គេពិតជាត្រឹមត្រូវមែន ហើយស្ថានភាពជាក់ស្តែងនេះកើតមានឡើងតាំងពីកន្លះសតវត្សរ៏មកហើយ គឺចាប់ពីថ្ងៃ ៤មិថុនា ១៩៤៩ មកម្ល៉េះ គឺពេលដែលខ្មែរបានបាត់ដែនដីកូសាំងស៊ីនទៅឱ្យប្រទេសយួន ។ ប្រទេសកម្ពុជាសព្វថ្ងៃ កំពុងមានជំងឺរាជា កុម្មុយនិស្ត ខ្មែរក្រហម ហើយនឹងស្លាប់តែហោងថ្ងៃណាមួយដោយជំងឺមហារីកនេះ ។ មេក្បត់សំខាន់ៗពីរ គឺវ៉ាតិមហុង និង ហ៊ុនសែន កំពុងធ្វើសមយុទ្ធ ដើម្បីកាត់ភូមិ ខ្មែរ២ គឺភូមិថ្លុកត្រាចនិងអន្លង់ជ្រៃ ដែលជាភូមិកំណើតនិងរស់រានរបស់ ហេងសំរិន ឱ្យទៅយួន ដោយយោងទៅលើសន្ធិសញ្ញា បំពេញបន្ថែមឆ្នាំ២០០៥នេះឯង ។ ការប្រគល់ភូមិនិងទឹកដីដទៃទៀត នឹងធ្វើជា បន្ត បន្ទាប់តាម ដំណើរឈាន ទៅមុខនៃ ការដាំបង្គោលព្រំដែន ដែលគេគ្រោងទុកថានឹងបញ្ចប់ឱ្យបាន នៅដំណាច់ឆ្នាំ២០១២នេះ ។ ផែនទីថ្មីមួយនឹងត្រូវតាក់តែងឡើងដោយយួននិងរបបហ៊ុនសែន ។ ដូច្នេះបំណែក នយោបាយទី១ បង្ហាញ ច្បាស់ថាវាឥត ប្រយោជន៍ ហើយប្រហែលជាចង្រៃដល់ប្រជាជាតិខ្មែរទៀតផង ។ វាពុំ អាចជួយប្រទេស យើងបានតាមប្រការណាមួយទេ ។ ដូច្នេះនេះជា ហេតុផល ចាំបាច់ គ្រប់គ្រាន់ និងស្របច្បាប់ណាស់ សំរាប់ ឱ្យប្រជាជាតិខ្មែរយើង ចាប់ផ្តើមបំផុះបដិវត្តន៏រំដោះ ប្រទេស ។ គ្មានលេសអ្វីទាំងអស់ ដែលនាំឱ្យខ្មែរទាំងអស់គ្នាគេចហើយ ឈរ ឱបដៃ មិនធ្វើបដិវត្តន៏រំដោះប្រទេស នេះទេ ព្រោះ ប្រវត្តិសាស្រ្តនឹងចោទយើងទៅអនាគត ថា បានក្បត់មាតុភូមិ ទាំងអស់គ្នា ។ គឺមានតែបដិវត្តន៏ផ្កាឈូក បំផុះដោយ ប្រជា ពលរដ្ឋខ្មែរទាំងអស់គ្នានេះទេ ដែលអាចដណ្តើមយកជ័យជំនះ ចុងក្រោយជា អវសានបាន ។ .

## ខ / យុទ្ធវិធីរបស់ពលរដ្ឋ

### ១/ចលនាជាតិពហិការបានទទួលសំឡេងជាងពាក់កណ្តាលនៃអ្នកចុះឈ្មោះបោះឆ្នោត

តួរលេខនៃការចូលរួមបោះឆ្នោតឃុំសង្កាត់ត្រឹម ៥១,២៣% បង្ហាញជំរែងអន្លាយពីជោគជ័យនៃ ចលនាជាតិពហិការ ។ គឺជាជោគជ័យនៃពលរដ្ឋដែលបះបោរធ្វើបដិវត្តន៏ ។ ដូច្នេះគណបក្សទាំងអស់មានបក្សរណប បក្សកាន់អំណាច និង បក្ស ប្រឆាំង រួមគ្នា ពុំអាចតំណាងឱ្យប្រជាពលរដ្ឋខ្មែរទាំងមូលបានទេ ។ បើគេយកមកបូកបញ្ចូល ពីភាពមិនទៀងទាត់ដូចជាវិញ្ញាបនប័ត្រ បញ្ជាក់ការបោះឆ្នោត (រូបមន្តជំនួសទំរង់១០១៨ ) ការព្រមាន សំឡុតបំភ័យ វត្តមាននៃអាណិកជនយួនមកបោះឆ្នោត កលល្បិច ប្តូរការិយាល័យបោះឆ្នោត លុបឈ្មោះអ្នកបោះឆ្នោតឱ្យបក្សប្រឆាំងចេញពីបញ្ជីរ ទិញសន្លឹកឆ្នោត បំប៉ោងតួរលេខ ជាផ្លូវការនៃអ្នកចុះឈ្មោះបោះឆ្នោត ប្រើប្រាស់ច្បាប់បោះឆ្នោតដើម្បីប្រមូលយកអាសនៈឱ្យបក្សប្រជាជន តាមការរាប់យក សំឡេង ឆ្នោតស្អុយ( ៣លាន សំឡេងនៃបក្សប្រជាជន ប្រមូលបាន១៥៩២មេឃុំសង្កាត់ រីឯ២លានសំឡេងនៃគណបក្សប្រឆាំង បានទទួល មេឃុំសង្កាត់ត្រឹម៤០) ដឹកជញ្ជូនអ្នកបោះឆ្នោតឱ្យបក្សប្រជាជនដែលមានឈ្មោះនៅតាមច្រើនការិយាល័យ បន្លំលទ្ធផល ។ល ។ ដូច្នេះ គណបក្សទាំងអស់រួមគ្នា បានទទួលសំឡេងតិចជាងពាក់កណ្តាល នៃអ្នកចុះឈ្មោះ (បក្សប្រឆាំងទទួល ២ លានសំឡេង បក្សប្រជាជន ៣ លានសំឡេង នៅសល់ជាង៤លាននាក់ដែលមិនទៅបោះឆ្នោត) ។ និយាយឱ្យខ្លី បើគេបូកបញ្ចូលខ្មែរនៅ

ឯនាយសមុទ្រ និង យុវជនខ្មែរ ដែលមានអាយុតិចជាង១៨ឆ្នាំ ដែលមិនមានសិទ្ធិបោះឆ្នោត តែដែលបារម្ភពីបញ្ហាជាតិដែរនោះ គណបក្សជាតិពហិការ (គជព) តំណាងឱ្យប្រជាពលរដ្ឋបានសំឡេងច្រើនលើសជាងពាក់កណ្ដាល។ ប្រជាពលរដ្ឋខ្មែរ ដែលគាំទ្រ ចលនាជាតិពហិការ ហើយទាមទារឯករាជ្យ សេរីភាព និងលទ្ធិប្រជាធិបតេយ្យ ពិតជាកំលាំងទី១ដែលទទួលបានជ័យជំនះ នាពេលនេះ។

## ២/ពន្ធនាគារព្រៃសរ ជានិមិត្តរូបនៃ ពន្ធនាគារបាស្ទីយ៍បារាំង

ការប្រៀបប្រដូចពន្ធនាគារព្រៃសរទៅនឹងពន្ធនាគារបារាំងបាស្ទីយ៍មានមូលហេតុមកពីមានការចាប់ខ្មែរអ្នកប្រឆាំង និង អ្នកតវ៉ាដូចជាម្ដាយៗជាអ្នកស្រុកនៅតំបន់បឹងកក់ជាដើម បញ្ចូលគុកដ៏អាក្រក់ល្បីល្បាញនេះដោយអយុត្តិធមិនិងផ្ដាច់ការ ។ គឺជាចំណុចទ្រទ្រង់អ្នកបដិវត្តន៍ខ្មែរក្នុងការតស៊ូដើម្បីយុត្តិធមិនិងការរំដោះ ។ គេនឹងបើកចំហរគុកបាស្ទីយ៍នេះនៅពេល ដែល បដិវត្តន៍ផ្កាឈូក ឈ្នះ ហើយគេនឹងដោះលែងអ្នកជាប់ពិរុទ្ធដោយអយុត្តិធមិ និងយកអ្នកដើរតួក្នុងរបបរាជាកុម្មុយនិស្ដ បក្សប្រជាជន ហ៊ុនសែនសព្វថ្ងៃដាក់ជំនួសវិញ។ បដិវត្តន៏ផ្កាឈូក នឹងបន្តដំណើរទៅមុខទៀតតាមលំអានកុមារាកុមារីដែល ធ្វើបាតុកម្មតវ៉ា ទាមទារ ឱ្យគេដោះលែងមាតារបស់គេនៅតំបន់បឹងកក់។ បដិវត្តន៏ផ្កាឈូក នឹងទាមទារយកមកវិញ តាមរយៈ សន្ធិសញ្ញា និងស្ថាប័នអន្តរជាតិ នូវដែន សមុទ្រនិងដែនដី មានភូមិនានា ដែលយួន បានកាត់យករហូតដល់ចុងឆ្នាំ២០១២។ ពន្ធនាគារព្រៃសរគឺជានិមិត្តរូប នៃ អំណាចផ្ដាច់ការ បក្សប្រជាជនហ៊ុនសែនដែលមិនត្រឹមតែយកអង្គរក្ស ប៉ូលីស និងកងទ័ព ដើម្បីបង្ក្រាបប្រជាពលរដ្ឋ ប៉ុននោះទេ តែបានប្រើប្រាស់តុលាការដើម្បីចាប់ជនទន់ខ្សោយ យកទៅដាក់គុកដោយគ្មាន បានគិត ពីសិទ្ធិមនុស្សឡើយ។ ដូច្នេះគុកព្រៃសរ ជា និមិត្តរូប តំណាងគុកបាស្ដីយ៍ខ្មែរដែលអ្នកបដិវត្តន៍ត្រូវតែ រំលាយចោល។ អ្នកដឹកនាំជាឧក្រិដ្ឋជន អ្នកឧកញ៉ាម៉ាហ្វីយ៉ា សមាជិកបក្សពុករលួយ នៃរបបប្រជាជនហ៊ុនសែន មិត្តភ័ក្ដិវិនិយោគិន និងគ្រួសារ ជាអ្នកសមគំនិតនឹង ត្រូវទៅទទួលនិងលុបលាងទោស នៅទីនោះ។

## ៣/ស៊ូណាមីប្រជាពលរដ្ឋ ដៃកាន់ផ្កាឈូក

តើយើងត្រូវធ្វើយ៉ាងណាដើម្បីសំរេចឱ្យបាននូវគោលដៅពយ៉ាងបៃដិវត្តន៏ផ្កាឈូក ?

- កំលាំងឬហឹង្សា ពុំអាចមានជ័យជំនះលើយួននិងបក្សប្រជាជនហ៊ុនសែនបានទេ។

- បើយើងរួមគ្នា យើងនឹងឈ្នះ។ យើងត្រូវអនុវត្តយុទ្ធវិធីស្រមោចភ្លើងដែលប្រយុទ្ធតទល់នឹងខ្លា។ ស្រមោចភ្លើ ង៣-៤ពុំអាចរំខានខ្លាបានទេ ទោះជាសកម្មយ៉ាងណាក៏ដោយ។ តែស្រមោចភ្លើងរាប់ម៉ឺនអាចដេញខ្លាបាន។ យើងត្រូវតែស្រែក ធ្វើការ ទាមទារគ្រប់ទីកន្លែង នៅទីលានសាធារណៈ នៅមុខវិឡាភូមិគ្រឹះហ៊ុនសែន ជាស៊ីម ហេងសំរិន មុខទីស្នាក់ការបក្សប្រជាជន មុខមន្ទីរព្រឹទ្ធ សភា មុខសភាតំណាងរាស្ត្រ មុខវាំង្គ មុខវិមានសន្តិភាព (ទីស្នាក់ការរដ្ឋាភិបាល) នៅមុខគ្រប់ស្ថានទូតយួនក្នុងស្រុកខ្មែរនិង នៅបរទេស នៅមុខទីស្នាក់ការអង្គការសហប្រជាជាតិ ។ល។ យើងត្រូវធ្វើមហាបាតុកម្មស៊ូណាមី ដោយមាន បដា ទាមទារឯករាជ្យជាតិ អធិបតេយ្យ និងបំបាត់អំពើផ្ដាច់ការ។ ម្នាក់ៗ ពាក់អាវយឺតមានរូបផ្កាឈូក ឆ្នៃប្រឌិតទៅតាម ចំណង់នៃ អង្គការក្រៅ រដ្ឋាភិបាលឬ សមាគម និមួយៗ ដោយមានម៉ាស៊ីនថត ទូរស័ព្ទ ដៃកាន់ផ្កាឈូក ក្នុងបរិយាកាសអហឹង្សា ស្របតាម វប្បធមិពុទ្ធសាសនា ដើម្បី បង្ហាញ ពីឆន្ទៈប្រជាពលរដ្ឋខ្មែរ ដោយយកសិទ្ធិមនុស្សជាមូលដ្ឋាន។ ព្រះអង្គលួនសាវ៉ាត បាន បង្ហាញជាឧទាហរណ៏ ដោយបាន ចូលរួមហែរកាន់ផ្កាឈូក ជាមួយប្រជាពលរដ្ឋនៅបឹងកក់។ វិចិត្រករគំនូរអ៊ឹងប៊ុនហៀង (សក្រវ៉ា) បានបញ្ចេញស្នាដៃជាគំនូរតួកតាមដានគាំទ្រព្រឹត្តិការណ៏ជាតិជារៀងរហូត។ ក្រុមអ្នកកវី(ផ្ទះកវីខ្មែរ) បានសំដែង

សរសេរយោបល់ មនោ សញ្ចេតនា ពីក្នុងជំរៅចិត្ត ចូលរួមប្លែកពិសេសនិងនាំផ្លូវយ៉ាងសកម្ម។ សិល្បករចំរៀង កុយវណ្ណា បានបង្ហូរមនោសញ្ចេតនា ស្នេហាជាតិរបស់ខ្មែរ ទូទៅ ជាបទចំរៀងជាង៦០ មកហើយ ដែលក្នុងនោះ មានការយំសោក ក្តៅក្រហាយ រួមទុក្ខជាមួយ កុមារា កុមារីកូនចៅអ្នកភូមិបឹងកក់និងបូរីកីឡា។ យើងក៏សុំនិយាយ ពី សកម្មភាពចំៗ នៃគណបក្សនយោបាយ ផងដែរ ដូច ជាទង្វើរបស់ លោកស្រីមូសុខហួរ ជាតំណាងរាស្ត្រមកពីគណបក្សសមរាំងស៊ី ដែលបានធ្វើសកម្មភាពជាអន្តរជាតិ ជួបជាមួយលោក ស្រីគ្លិនតុន ជាដើម ។

-ប្រជាពលរដ្ឋខ្មែរ ពេលនេះគួរផ្អាកកុំធ្វើបតុកម្មគាំទ្រគណបក្សណាទាំងអស់ ព្រោះវាជាបុព្វហេតុចម្រែងអាក្រក់ នាំឱ្យមាន ការខ្វែងយោបល់ ឈ្លោះប្រកែកគ្នាឥតប្រយោជន៏។ គេត្រូវតំរង់ការតស៊ូទៅលើកង្វល់ និងសិទ្ធិជារៀងរាល់ថ្ងៃផ្ទាល់ខ្លួន និងទៅលើគោលដៅធំៗបីរបស់ជាតិ មានឯករាជ្យ ការរំលំរបបផ្តាច់ការ និង ការបង្កើតរបបសេរីនិងប្រជាធិបតេយ្យ។ បដិវត្តន៏ផ្កាឈូក ប្រកាន់យកប្រយោជន៏ប្រជាពលរដ្ឋជាធំ មិនគាំទ្រប្រយោជន៏អ្នកដឹកនាំ ឬប្រទេសមហាអំណាចណាមួយទេ។ មកទល់ថ្ងៃនេះ យើងឃើញតែក្រុម ស្ថាប័ន និង រដ្ឋបរទេសនានា មានចិនយួនជាដើម ដែលតែងតែទាញប្រវ៉ញ្ញយកចំណេញពីការប្រឹងប្រែង ពី ប្រយោជន៏ និងជីនះរបស់យើង ទៅបំរើការលោភលន់របសគេ។ អំពើប្រល័យពូជសាសន៏ក្នុងរបបប៉ុលពត និងការបាត់បង់ ទឹកដីទៅឱ្យយួន គឺជាឆ្អឹងត្រីដែលកំពុងស្ទាក់ក្នុងបំពង់កខ្មែរ។

- ពេលណាគោលដៅទាំង៣នេះបានសំរេចហើយ ពលរដ្ឋនឹងទទួលយកសេរីភាពរបស់គេឡើងវិញ ដើម្បីបោះឆ្នោតរើសអ្នកដឹកនាំណាដែលគេស្រឡាញ់ចង់បាន។ គេត្រូវតែគិតគូរការពារកេរ្តិ៍តំណែលបដិវត្តន៏ ផងដែរតាមរយៈស្ថាប័នដើម្បី កុំឱ្យជនផ្តាច់ការដទៃទៀតអាចប្រមូលយកអំណាចពីប្រជាពលរដ្ឋម្តងទៀត។ ព្រោះសព្វថ្ងៃនេះ ប្រទេសកម្ពុជាបានក្លាយ ជានំដែលគេកាត់ ចែកគ្នាជាដុំធំៗរួចអស់ហើយ។ ដុំនិមួយៗជាកម្មសិទ្ធិផ្តាច់មុខរបស់អ្នកដឹកនាំមួយ។ ឧទាហរណ៏ គឺសុខអាន ហ៊ុនសែនបក្សប្រជាជននិងគ្រួសាររបស់គេដែលបរិភោគនំមួយដុំធំជាងគេ។ ហោណាំហុង និងគ្រួសារបែងចែកយកទីស្តីការរដ្ឋ មន្ត្រីក្រសួងការបរទេស។ ចម ប្រសិទ្ធ និងគ្រួសារ ប្រមូលយកទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជកម្ម។ ស៊ុយសែមនិងគ្រួសារ ត្រួតត្រាក្រសួងឧស្សហកម្ម។ ហ៊ុនសែន ទាបាញ់ គន់គីម.. ក្តោបក្តាប់កងទ័ព ។ ចាន់ សារុន និងគ្រួសារ ត្រួតត្រារកស៊ីលើក្រសួងកសិកម្ម នេសាទនិងព្រៃឈើ ។ សុខគង់ ជនជាតិ យួននិងគ្រួសារ ទាញយកផលប្រយោជន៏ពីប្រាសាទអង្គរវត្ត។ រីឯកាកបាទក្រហមខ្មែរ គឺលោកស្រីប៊ុនរ៉ានីហ៊ុនសែន ដែលគ្រប់ គ្រងជាប្រយោជន៏នយោបាយបក្សប្រជាជន។ល។ ដូច្នេះទៅអនាគត ត្រូវតែមាន រដ្ឋាភិបាលអន្តរកាលមួយ ជាចាំបាច់ ដើម្បី ដឹកនាំបដិវត្តន៏ឱ្យទទួលបានជោគជ័យ ដូចជាគ្រប់គ្រងកិច្ចការទូទៅ រៀបចំការបោះឆ្នោតរើសសភាធម្មនុញ្ញ តាក់តែងរដ្ឋ ធម្មនុញ្ញថ្មី មួយ និង បង្កើតស្ថាប័នថ្មីនានា។ល។ គេត្រូវលុបបំបាត់ចោលបុព្វសិទ្ធិនានាទាំងអស់ ហើយបន្ថយចំនួន អាណត្តិប្រធានាធិបតី ឬប្រមុខរដ្ឋ ដើម្បិកំចាត់កុំឱ្យមានអំពើផ្តាច់ការ ពុករលួយ និងក្បត់ជាតិបន្តទៀត។ ប្រទេសកម្ពុជាត្រូវតែក្លាយជានិតិរដ្ឋ មិនមែននៅដដែលជារដ្ឋអត្តាធិបតេយ្យ ដូចដែលហ៊ុនសែនជនផ្តាច់ការចាប់បង្ខិលអូស ទាញ ស្រេចក្បាលចិត្តនោះទេ។ យ៉ាងហោចណាស់ក៏គេត្រូវធ្វើច្បាប់បោះឆ្នោតមួយ ដាក់ប្រយោជន៏ជាតិ ឱ្យនៅពីលើ ប្រយោជន៏ គណបក្សដែរ។

-ប្រជាជាតិខ្មែរត្រូវតែហ៊ានធ្វើបាតុកម្មស៊ូណាមី ដូចដែលកុមារាកុមារីនៅភូមិបឹងកក់និងប្រជាពលរដ្ឋនៅបូរីកីឡា បានផ្តើមធ្វើដើម្បីរំដោះម្តាយ១៣នាក់ដោយអហឹង្សា ហើយដែលមានការគាំទ្រពីអង្គការការពារសិទ្ធិលំនៅឋាន ដែល បង្កើតឡើងដោយ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិចំនួន១២។

-បដិវត្តន៏ផ្កាឈូកសូមរួមសាមគ្គី ជាមួយបុគ្គលិកសិក្ស។ ពលករគ្រប់រោងច័ក្រទាំងអស់ ដែលនាំគ្នាធ្វើបាតុកម្មដើម្បីទាមទារបៀវត្សរ៍ឬប្រាក់បំណាច់បន្ថែមសំរាប់សុំរស់កុំឱ្យស្លាប់ ។ បដិវត្តន៏ផ្កាឈូកគាំទ្រ លោករ៉ុងឈុន ប្រធានដឹកនាំ ដែលលើសពីសេចក្ដី កង្វល់ នៃសហជីព លោកជាសក្ខីជនតាមដានការកាត់យកទឹកដីខ្មែរដោយប្រទេសយួន។ យើង គោរព សរសើរគំនិតស្នេហា ជាតិនិងកិច្ចការត្រឹមត្រូវនៃគណកម្មការព្រុំដែនខ្មែរនៅស្រុកបារាំង ព្រមទាំងប្រធានលោកសឿនប៉េងសែ។ យើងគាំទ្រលោកម៉មសុណង់ដូ និងសមាជិកនានានៃសមាគមអ្នកប្រជាធិបតេយ្យ របស់លោក ក្នុងការប្រយុទ្ធ នៅលើទឹកដី ដើម្បីសិទ្ធិ និងលទ្ធិប្រជាធិបតេយ្យ។ យើងសរសើរ ចលនាអំណាចពលរដ្ឋខ្មែរ និងប្រធានចលនានេះគឺលោកសួនសេរីរដ្ឋា ពីសេចក្ដី ក្លាហាននិងការប្រយុទ្ធមិនចុះញ៉ូមដើម្បីដណ្ដើមយកសិទ្ធនិងអំណាចជូនប្រជាពលរដ្ឋ។ ចលនាអំណាចពលរដ្ឋខ្មែរ បានដាក់ពាក្យ ប្ដឹងកាលពីថ្ងៃ២២មិថុនា ២០១២ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅទីក្រុងឡាអេប្រទេសហុឡង់ ពីបទឧក្រិដ្ឋកម្មនានា មានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើមដែល ប្រព្រឹត្តដោយរបបបក្សប្រជាជនហ៊ុនសែន។ មកទល់ពេលបច្ចុប្បន្ននេះ ហ៊ុនសែនតែងតែ ប្រើអំណាចផ្ដាច់ការចេញបញ្ជា ព្រះ រាជអាជ្ញា កំលាំងទ័ព តុលាការ ដើម្បីយកអ្នកប្រឆាំងនិងបាតុករ ទៅដាក់គុកព្រៃសរ។ លោកសមរង្ស៊ី ដែលសព្វថ្ងៃនិរទេស ខ្លួនឯងមកនៅប្រទេសបារាំង គឺដោយតុលាការខ្មែរកាត់ទោស គាត់ឱ្យជាប់ពន្ធនាគារ ជាង១២ឆ្នាំ។ ក្នុងឋានៈខ្លួនជាអ្នកដឹកនាំ ប្រទេស ហ៊ុនសែនមិនដែលឈឺក្បាលឬយកចិត្ត ទុកដាក់ដើម្បីរកឱ្យឃើញនិងចាប់ចង អ្នកជាប់ចោទទទួលខុសត្រូវក្នុងឃាតកម្ម សង្ស័យនយោបាយ មាន អ្នកកាសែតធុនប៊ុនលី ក្នុងឆ្នាំ ១៩៩៧ លោកហូសុខក្នុង រដ្ឋប្រហារ ថ្ងៃ ៥-៦ កក្កដា១៩៩៧ បាតុករនៅមុខរដ្ឋសភាជាតិ ឆ្នាំ១៩៩៧ សិល្បការិនីពិសិដ្ឋពលិការ ឆ្នាំ១៩៩៩ អ្នកចំរៀង ទូចស្រីនិច និងម្ដាយ ក្នុងឆ្នាំ២០០៣ ព្រះសង្ឃសម ប៊ុនធឿនឆ្នាំ២០០៣ លោកឱម សារាឌី ឆ្នាំ២០០៣ លោកជាវិជ្ជា មេដឹកនាំ សហជីព ឆ្នាំ២០០៤ ។ល។

-ក្នុងនាមសាមគ្គីជាតិ យើងសូមស្នើរសុំឱ្យបាតុករគ្រប់ទិសទីនាំគ្នាកាន់ផ្កាឈូក ក្នុងការទាមទារដើម្បីប្រយោជន៏ជាតិ ឬប្រយោជន៏ផ្ទាល់ខ្លួន ទាំងអស់ ដោយស្របច្បាប់ក្នុងផ្នែកសង្គមកិច្ច ផ្នែកបៀវត្សរ៍ ដោយនៅតែរក្សាអត្តសញ្ញាណដើមនៃបាតុករ ដដែល ដើម្បីបង្ហាញជានិមិត្តរូបឱ្យអន្តរជាតិមើលឃើញពីការរួបរួមនៃខ្មែរក្នុងស្រុកនិងខ្មែរក្រៅស្រុក ដោយយកឧទាហរណ៏តាមកុមារា កុមារី ជាកូននៃស្ដ្រីជាម្ដាយនៅតំបន់បឹងកក់ ដែលមានការគាំទ្រពីខ្មែរនៅ បរទេស មានកវី អ្នកគំនូរត្លុក អ្នកចំ រៀង ព្រះសង្ឃ អ្នកប្រើ ប្រាស់អន្តរបណ្ដាញ ហ្វេសប៊ុក ទ្វីទ័រ អ្នកកាសែត ខេអាយមីឌា វិទ្យុខ្មែរប៉ុស្ដ វិទ្យុខ្មែរពិភពលោក វិទ្យុចលនាអំណាចពលរដ្ឋ វិទ្យុអាស៊ីសេរី សំឡេងសហរដ្ឋអាមេរិក សមាគមខ្មែរនានាទូទាំងពិភពលោក អ្នកបដិវត្តន៏ផ្កាឈូកទូទាំពិភពលោកដែលខ្លះឋិតជាអនាមិក ខ្លះចេញមុខ ខ្លះលាក់មុខ ។ល។ ទង្វើបែបនេះបាន និងនឹងនាំមកនូវផលប្រយោជន៏ដ៏ធំធេងសំរាប់ប្រទេសកម្ពុជានិងប្រជាជាតិ។ គឺជាទឹកអូរតូចៗដែលហូរចាក់ទៅ ក្នុងទន្លេដែលបញ្ជូនបន្តទៅក្នុងមហាសាគរដ៏ធំធេង។ ប្រជាពលរដ្ឋខ្មែរត្រូវតែរួបរួមគ្នា ស្រលាញ់គ្នា ក្នុងប្រពៃណីសាមគ្គី ក្នុងវប្បធមិពុទ្ធសាសនា មានផ្កាឈូកជនិមិត្តរូប ហើយមិនត្រូវឈប់សំរាកកណ្ដាលផ្លូវដែលឆ្ពោះទៅរកជោគជ័យជាអវសាននេះទេ។

## ៤/យុទ្ធវិធីជោគជ័យ ដោយប្រជាពលរដ្ឋ

ចលនាពហិការមិនបោះឆ្នោតនៃប្រជាពលរដ្ឋប្រមូលសំឡេងបានលើសពីពាក់កណ្ដាលនៃប្រជាជាតិខ្មែ។ គឺជាចលនាប្រឆាំងនិង មិនចុះញ៉ូមទៅនឹងរបបសព្វថ្ងៃ។ ដូច្នេះសមយុទ្ធនយោបាយណាបព្វាសចរន្តនេះ ដែលមានបំណងធ្វើឱ្យរបបហ៊ុនសែន រស់រានបន្ត គឺ ជាការនាំឱ្យខាតពេល ឬជាអំពើក្បត់តែម្ដង។ មាតុភូមិយើងនឹងស្លាប់ដោយជៀសមិនផុតទេ ដោយរបបរាជា កុម្មុយនិស្ត នេះឯង។ ប្រជាពលរដ្ឋខ្មែរត្រូវតែបន្តបដិវត្តន៏ផ្កាឈូកនេះដោយសន្តិវិធី។ កង្វល់ធំរបស់បដិវត្តន៏ ផ្កាឈូក

គឺការការពារ ជីវិតរបស់ បាតុករ ព្រោះរបប ផ្តាច់ការ បក្សប្រជាជនហ៊ុនសែន ដែលក្តោបក្តាប់អំណាចគ្រប់បែបយ៉ាង នឹងប្រើកំលាំង ក្នុងកណ្តាប់ដៃ គេ ដើម្បី វាយ បង្ក្រាប ។ តែ បញ្ច្រាសទៅវិញ អំពើរឃោឃៅបែបនេះ នឹងរឹតតែរុញច្រានឱ្យរបបហ៊ុនសែន រលំឆាប់ឡើង១ដោយជៀស មិនផុត ។ អង្គការ ពតិមាន អន្តរជាតិនឹងថិតនៅជាមួយយើង ហើយនឹងអាច បង្ហាញអ្វី១ជាសាក្សីនៅមុខសហគមន៍អន្តរជាតិ និងតុលាការអន្តរជាតិ ។ អង្គការរបស់បដិវត្តន៏ផ្កាឈូក ដែលមានឈ្មោះថា ផ្កាឈូកដែលចុះបញ្ជីតាមច្បាប់បារាំង អាចនឹងទទួល ភារកិច្ច ដាក់បណ្តឹង ជាអន្តរជាតិប្រឆាំងឧក្រិដ្ឋជន ដែលប្រើប្រាស់ធនធាន និងស្ថាប័នរដ្ឋដើម្បីធ្វើជាទ្រព្យសម្បត្តិ ផ្ទាល់ខ្លួន ហើយថែម ថែមទាំង ប្រើ សំរាប់បង្ក្រាបជនរួមជាតិឯងនៅក្នុងថ្លុកឈាមទៀតផង ។ បដិវត្តន៏ផ្កាឈូកសូមឱនកាយគោរព សេចក្តី ក្លហាននៃអ្នកស្រុកបឹងកក់ ដែលមានកុមារាកុមារី ក្មេង១ ជាបុត្រធីតា របស់ស្ត្រី១ជាម្តាយដែលជាប់ក្នុងពន្ធនាគារព្រៃសរ នាំគ្នា ធ្វើបាតុកម្ម យំរហាម ដៃ កាន់ផ្កាឈូក ខ្លះពាក់អាវយឺតរូបផ្កាឈូក ។ យើងគោរពសរសើរការគ្រប់គ្រងដោយប្រសិទ្ធិភាព លើ បាតុកម្មទាំង នេះដោយ ក្រុម កាពារសិទ្ធិលំនៅថានដែលបង្កើតដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិចំនួន១២ ។ ប្រជាជនបូរីកីឡា ក៏បាន ធ្វើបាតុកម្មរបៀបនេះដែរ ។ បាតុករទាំងនេះបានដង្ហោយហៅយើងជាខ្មែរទាំងអស់គ្នាដោយផ្ទាល់តែម្តង ។ នេះគ្រាន់តែជារលក ស៊ូណាមី ដ៏តូចមួយដែលផុះចេញពីបាត្រសមុទ្រប្រជាពលរដ្ឋដែលកំពុងតែក្លាយជារលកស៊ីមស្តែដ៏ធំមហិមា បក់បោក ទៅលើរបបផ្តាច់ការ បក្សប្រជាជន ហ៊ុនសែន ដើម្បីបណ្តេញ យួនឈ្លានពានចេញពីស្រុកខ្មែរ ។ មានតែបដិវត្តន៏ផ្កាឈូករបស់ពលរដ្ឋនេះទេ ដែលអាចឆ្លើយតប និងដោះស្រាយបានជាទូទៅ និង ត្រឹមត្រូវ ចំពោះការរង់ចាំ នៃប្រជាពលរដ្ឋ ខ្មែរ ។

### គ /បង្គោលបី នៅតាមផ្លូវ ក្នុងដំណើរឆ្ពោះទៅរកជោគជ័យនៃបដិវត្តន៏ផ្កាឈូក

បដិវត្តន៏ផ្កាឈូក ជំរុញឱ្យប្រជាជាតិធ្វើសង្គ្រាមស្អាតនិងដោយសន្តិវិធី ក្នុងការរំដោះប្រឆាំងយួន និង រំលំរបបគណបក្សប្រជាជនហ៊ុនសែនផ្តាច់ ការ និង ក្បត់ជាតិ ។ ពលរដ្ឋខ្មែរមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការ ប្រយុទ្ធតាមគ្រប់ មធ្យោបាយដើម្បីបំរើបុព្វហេតុស្របច្បាប់ ត្រឹម ត្រូវ របស់ខ្លួន ។ មិនមែនជា ការប្រកាន់ពូជសាសន៏ទេ បើពលរដ្ឋខ្មែរខឹង ស្អប់ ហើយនាំគ្នាបណ្តេញយួនដែលកំពុងធ្វើអាណានិគម និង ចំរាញ់ យក ធនធានជាតិរបស់គេ ហើយ បន្តត្រួតត្រាអំណាចរដ្ឋរបស់គេ បន្ទាប់ពីបានកាត់យកសមុទ្រ កោះនិងដីព្រុំប្រទល់រួចមក ។ មិនមែនជា អំពើ ភេរវកម្មទេ ដែលប្រជាពលរដ្ឋខ្មែរការពារខ្លួន ប្រឆាំងតបត អំណាចផ្តាច់ការ ។ ប្រជាពលរដ្ឋខ្មែរ ត្រូវ អនុវត្តឱ្យ សំរេច បាននូវ បេសកកម្ម ៣ យ៉ាង តាម លំដាប់ដូចតទៅ គឺទី១ ដណ្តើម យកឯករាជ្យ ទី២ កសាង និតិរដ្ឋ និង ទី៣ លទ្ធិ ប្រជា ធិប តេយ្យ ។

#### ១/ឯករាជ្យនៃកម្ពុជា មុនដំណាច់ឆ្នាំ២០១២

ប្រទេសយួននិងរបបអាយ៉ងបក្សប្រជាជនហ៊ុនសែនបាន គ្រោងធ្វើការបោះបង្គោលកំណត់ព្រំដែន ៣៧៥ លើព្រំដែនប្រវែង ១២៧០គម ឱ្យបានចប់មុនដំណាច់ឆ្នាំ២០១២ ។ ក្នុងឱកាស សម្ភោធបង្គោល លេខ៣១៤ ហ៊ុនសែននិងវ៉ាតិមហុង បានចាប់ផ្តើមប្រើកលល្បិចកាត់ភូមិព្រំប្រទល់២ គឺថ្លុកត្រាចនិងអន្លង់ជ្រៃ ឱ្យទៅយួនឬក៏ដូរ ជាមួយទីកន្លែងដ៏ទៃទៀត ។ គួរឱ្យអនិច្ចាគណបក្សរណបនិងគណបក្សប្រឆាំង នាំគ្នាបិទភ្នែក ហើយសំរេចថានឹងចូលរួមក្នុងសម័យបោះឆ្នោតរើសតំណាងរាស្ត្រ នៅថ្ងៃ២៨កក្កដាឆ្នាំ២០១៣ ទៀត ក្នុងគោល បំណងធំចំបងបែបអត្តទត្ថនិយមបក្សពួក ។ ទោះជាគេឈ្នះ ក៏គេនឹងមិន ធ្វើការរំដោះរបបនេះ ឱ្យចេញពីយួន និងពីរបបរាជានិយមឥតប្រយោជន៏និងហួសសម័យនេះដែរ ។ ដោយគណបក្សទាំងនេះជាអ្នកបង្កើតរបបសព្វថ្ងៃ ដូច្នេះ គេពុំអាចក្លាយជាគណបក្ស រំដោះ ប្រជនពលរដ្ឋ ចេញពី អាណានិគម រាជាកុម្មុយនិស្ត បក្សប្រជាជន

ហ៊ុនសែនយួនហាណូយ បានទេ.។ ដូច្នេះវាគ្មានប្រយោជន៏ អ្វីដែលប្រជាពលរដ្ឋត្រូវនាំគ្នាគិតគូរពី ការរួមគ្នា ជាសម្ព័ន្ធ ឬច្របាច់បញ្ចូលគ្នា រវាង បក្ស ប្រឆាំងទាំង២នោះទេ ព្រោះវានាំឱ្យយើងខាតពេលបន្តទៀត។ ដូច្នេះប្រជាពលរដ្ឋខ្មែរនៅតែជាតួសំខាន់តែមួយគត់ដដែលក្នុងការរ រំដោះ ប្រទេស ដោយ យក ធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលនៃសិទ្ធិមនុស្ស និង កិច្ចព្រមព្រៀងប៉ារីស ថ្ងៃ២៣ តុលា១៩៩១ ជាមូលដ្ឋាន។ គេត្រូវតែដេញយួននិងបក្សប្រជាជន ហ៊ុនសែនឱ្យបានមុនដំណាច់ឆ្នាំ២០១២ ដោយធ្វើ មហាបាតុកម្មសូណាមីប្រជាពលរដ្ឋ កាន់ផ្កាឈូកក្នុងដៃ និងពាក់អាវយឺតរូបផ្កាឈូកតាមចំណង់រឿង៧ខ្លួន។ ព្រោះថា ទោះជា មានកិច្ចព្រមព្រៀងនេះដែលខ្លួនជាហត្ថលេខីក៏ដោយ ក៏យួននិងបក្សប្រជាជនហ៊ុនសែននៅតែបន្តគ្រប់ ច្រក ល្ហក ប្រើ កល ល្បិច ជាង៣៤ឆ្នាំមកហើយដើម្បី កាត់ យកទឹកដីនិង បន្តអាណា និគមូបនីយកម្មនៃជនជាតិយួននៅ ក្នុងប្រទេសកម្ពុជាដែរ។ ប្រទេស ចិន និង ប្រទេសយួន កុម្មុយនិស្ត គេគិតតែ ប្រយោជន៏របស់ គេទេ។ បន្ទាប់ពីនាំឱ្យមាន របប ប្រល័យពូជសាសន៍ នៅ ស្រុកខ្មែរមក ប្រទេសទាំង២ នេះកំពុង ទទួល បាននូវដីសម្បទាន សំរាប់សាងសង់ ដីធ្វើកសិកម្ម ដីរ៉ែ សំរាប់ រកស៊ីអំឡុងពី៧០ ទៅ ៩៩ឆ្នាំ ដែលគេធ្វើអាជីវកម្មដោយប្រើបុគ្គលិករបស់គេ ដោយគ្មានខ្វល់ខ្វាយយកចិត្ត ទុកដាក់ ពីសង្គមកិច្ចរបស់ពលរដ្ឋខ្មែរ និង ពីបញ្ហាបរិដ្ឋានអ្វីទាំងអស់។

## ២/រំលំរបបផ្តាច់ការ ឱ្យបានមុនថ្ងៃ២៨កក្កដាឆ្នាំ២០១៣

បដិវត្តន៏ផ្កាឈូក គាំទ្រការរំលំរបបបក្សប្រជាជនហ៊ុនសែនឱ្យបានឆាប់ ដើម្បីបណ្តេញយួនជាបន្ទាន់ ឱ្យចេញពីស្រុខ្មែរ បើយូរណាស់ឱ្យបានមុនថ្ងៃ២៨កក្កដាឆ្នាំ២០១៣ ដើម្បីកុំឱ្យពលរដ្ឋខ្មែរបំពេញករណីយកិច្ច ធ្វើពហិការមិនបោះឆ្នោតនៅថ្ងៃនោះទៀត ហើយសំខាន់ បំផុតដើម្បីជៀសវាងកុំឱ្យវៀតណាមូបនីយកម្មនៅស្រុកខ្មែរតាមផ្នែកនយោបាយ សេដ្ឋកិច្ច និង ជនជាតិក្លាយជា គ្រោះថ្នាក់មិន អាចវិលត្រឡប់ក្រោយវិញបាន។ ព្រោះថា មុខប្រួញហាណូយគឺធ្វើយ៉ាងណាឱ្យគណបក្សប្រជាជនហ៊ុនសែនជាប់ឆ្នោត ម្តងហើយម្តងទៀត ដើម្បីពង្រឹងយួនូមនីយកម្មនៅស្រុកខ្មែរ។ ដូច្នេះយួនត្រូវតែអនុវត្ត យុទ្ធវិធី កែលំអលទ្ធិប្រជាធិបតេយ្យ តាមសំបកក្រៅ ដោយ ប្រើការបោះឆ្នោតប៉ាហ៊ុ ដើម្បីបំភាន់បន្លំភ្នែកអន្តរជាតិ។ លើកលែងតែការបោះឆ្នោតគ្រប់គ្រងដោយអង្គការ សហប្រជាជាតិក្នុងឆ្នាំ១៩៩៣ តែមួយនេះ ការបោះឆ្នោតទាំងអស់នៅក្រោយរដ្ឋប្រហារថ្ងៃ៥-៦ កក្កដា ១៩៩៧ សុទ្ធសឹងតែប្រឡាក់ ប្រឡូស ដោយការតែបន្លំនិងមិនមានតំលាភាពទេ។ បក្សប្រជាជនត្រូវតែធ្វើយ៉ាងណា ធ្វើ ឱ្យមានការរួបរួម គ្នាជតែសំបកក្រៅដូចអំពិលអំពែក រវាងគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សវ៉ាណារិត ដើម្បីអូស ទាញពលរដ្ឋខ្មែរឱ្យចូលក្នុងអន្ទាក់នៃការបោះឆ្នោត។ ដូច្នេះ ពលរដ្ឋខ្មែរត្រូវតែជៀសវាងឱ្យផុតជាដាច់ខាតពីល្បែងនេះ ហើយត្រូវ ដេញយួនចក្រពត្តិនិងរំលំរបប ផ្តាច់ការបក្សប្រជាជនហ៊ុនសែន ឱ្យបានមុនថ្ងៃ២៨កក្កដា២០១៣សិន។ ពេលណា ចក្រពត្តិយួន ចេញពីស្រុកខ្មែរ ហើយ ១ របបមួយ ដែលគោរព គោរពសិទ្ធិមនុស្ស នឹងត្រូវបានបង្កើតឡើង ពលរដ្ឋខ្មែរ នឹង ត្រូវតែទទួលបានសេរីភាព ពេញលេញគ្រប់គ្រាន់ ដើម្បី ជ្រើសរើសយក អ្នកដឹកនាំ តាមការបោះឆ្នោតដោយសេរីនិងមានតំលាភាព។ ដូច្នេះការបោះឆ្នោត ដោយសេរីពិតប្រាកដ នឹងអាច ធ្វើបាននៅតំណាក់ការទី៤ គឺក្រោយពេលរំដោះប្រទេសខ្មែរបាន។

## ២/អនុវត្តលទ្ធិប្រជាធិបតេយ្យក្នុងឆ្នាំ២០១៤ ក្រោយកាបង្កើតរដ្ឋសេរីនិងឯករាជមួយ

អ្នកជាប់ ឆ្នោត តាមភូមិនិងតាមសម្ហូហភាពឃុំស្រុក ក្នុងពេលបោះឆ្នោតថ្ងៃ៣មិថុនា២០១២ មិនអាចបំពេញ អាណត្តិនយោបាយ សេដ្ឋកិច្ច និង សង្គមកិច្ច ឱ្យបានត្រឹមត្រូវទេ( សំឡេង៣លានបានផ្តល់កៅអីមេឃុំឱ្យបក្សប្រជសជនចំនួន១៥៩២ ចំណែកបក្សប្រឆាំងដែល មានសំឡេងបោះឆ្នោត២លានបានទទួលកៅអីត្រឹម៤០ ប៉ុននោះ) ។ គឺពិតជាការបោះឆ្នោតប៉ាហ៊ី។

ព្រឹទ្ធសភា និង សភាតំណាងរាស្ត្រ បច្ចុប្បន្ន គឺជាស្ថាប័នប្រថាប់ត្រាបំរើរដ្ឋបក្សប្រជាជន ។ អ្វីៗ ទាំងអស់ចិត នៅក្នុងកណ្តាប់ដៃយួនហាណូយ និងបក្សប្រជាជនហ៊ុនសែន ។ បក្សប្រជាជនត្រូវតែធ្វើយ៉ាងណារៀបចំការបោះឆ្នោតឱ្យបានរហូត ក្រោមការត្រួតពិនិត្យ ដោយគជប ឧបករណ៍ក្រឡៃនិងបន្លំ ។ គណបក្សរណបនិងប្រឆាំង ខំធ្វើជាខ្ទាក់ជាគរ ដោយចេតនា ហើយស៊ូទ្រាំសុខចិត្ត ទៅបោះឆ្នោតទៀត ដើម្បីត្រឹមតែរក្សាបុព្វសិទ្ធិខ្លួននៅក្នុងរបបអាណានិគម ដោយយកលេសថាកិច្ចព្រមព្រៀង ទីក្រុងប៉ារីស បង្ខំ គេឱ្យធ្វើបែបនេះ ។ នេះជាកំហុសក្នុងយុទ្ធវិធីដ៏ធំធេងណាស់ ។ សំរាប់ប្រជាជាតិខ្មែរ គោលដៅទី១ ត្រឹមត្រូវ គឺធ្វើវិយូទ្ធបនីយកម្ម នៅស្រុខខ្មែរ គឺដេញយួនឱ្យចេញពីស្រុកខ្មែរ ។ រួចហើយរំលំរបបផ្តាច់ការ ។ និងជាបញ្ចប់ រៀបចំឱ្យមានការបោះឆ្នោតដោយសេរី ។

យើងត្រូវអនុវត្ត បទបញ្ជារ៥ យ៉ាងដែល បដិវត្តន៏ ផ្កាឈូក បានតាក់តែង ឡើង ដើម្បីសំរេច ឱ្យបាននូវ ដំណោះស្រាយបញ្ហាប្រឈម មុខធំៗ ទាំង៣ នេះ:

១/, បរិ ហារ តាមគ្រប់មធ្យោបាយទាំងអស់ ឱ្យសហគមន៏អន្តរជាតិ ដឹងថា ប្រទេសយួនគឺជាប្រទេស ចក្រពត្តិ និងអាណានិគមនិយមដែលកំពុង កាត់ យកទឹកដីខ្មែរ ។ ប្រទេសយួន ត្រូវតែចាកចេញពីប្រទេសខ្មែរ ។

២/, ប្រជាពលរដ្ឋខ្មែរ ត្រូវ បង្ហាញឱ្យនិគមជនយួនទាំងអស់ដឹងតាមគ្រប់មធ្យោបាយថា ប្រជាពលរដ្ឋខ្មែរ មិន ស្វាគមឱ្យពួកគេនៅក្នុងស្រុកខ្មែរទេ ។ ពលរដ្ឋ ខ្មែរត្រូវបង្ខំអ្នកដឹកនាំយួននិងអ្នកដឹកនាំខ្មែរ ឱ្យ បញ្ជូននិគមជន យួនទាំងនេះ ទៅ ស្រុកយួន វិញ ហើយ មិនត្រូវ បន្តចេញ អត្ត សញ្ញាណ ប័ណ្ណ និងសិទ្ធិបោះឆ្នោតឱ្យយួនទៀតទេ ។

៣/, ពលរដ្ឋត្រូវតែធ្វើឱ្យអ្នកដឹក នាំខ្មែរក្បត់ជាតិ អ្នកដឹកនាំយួន ហាណូយ ឱ្យដឹងតាម គ្រប់មធ្យោបាយ ហើយប្រាប់សហគមន៏អន្តរជាតិថា ពលរដ្ឋខ្មែរចង់បាន ឯករាជ្យ អធិបតេយ្យភាព និងបូរណភាព ទឹកដី កម្ពុជាវិញ ពោល គឺទាមទារលុបចោល សន្ធិសញ្ញា១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ និង សន្ធិសញ្ញា២០០៥ ។

៤/, នៅ ក្នុងស្រុក ពលរដ្ឋខ្មែរត្រូវតែ បំផ្លុះ ប្រតិបត្តិការ នានាស្របតាម ច្បាប់ អន្តរជាតិ ដែលធ្វើឱ្យមានការប៉ះពាល់ប្រយោជន៏ នយោបាយនិងសេដ្ឋកិច្ចនៃប្រទេសយួន ដោយមិនត្រូវទុកបណ្តោយឱ្យប្រយោជន៏ យួន ដុះដាល រុងរឿង ប្រកប ដោយសន្តិសុខក្នុងស្រុកខ្មែរបែបនេះឡើយ ។

៥/, បរិហារអ្នក ដឹកនាំខ្មែរក្បត់ជាតិ ឧក្រិដ្ឋជន ពុករលួយ ឱ្យពលរដ្ឋខ្មែរដឹង ឱ្យស្ថាប័ន អន្តរ ជាតិដឹង ដើម្បីផ្តន្ទាទំលាក់ ចេញពីអំណាច និងចាប់ចង រក្សាទុកទ្រព្យសម្បត្តិ ហាមឃាត់មិនឱ្យធ្វើដំណើរ ទៅបរទេស ចូល ស្រុក សេរីប្រជាធិបតេយ្យ ព្រោះពួកគេបាន ប្រព្រឹត្តអំពើឧក្រិដ្ឋ ប្រឆាំងមនុស្សជាតិ ធ្វើចរាចរគ្រឿងញៀន និងបាន ប្រព្រឹត្ត ការលាងលុយក្រខ្វក់ជាដើម ។

ដំបូងយើងត្រូវទាមទារយកសិទ្ធិទាំងអស់គ្នា បន្ទាប់មកយើងត្រូវតែប្រើប្រាស់សិទ្ធិនេះឱ្យបានពេញលេញ មានការធ្វើបាតុកម្ម ដោយគ្មានការក៏រិតបន្ថយសិទ្ធិ ទូទាំងប្រទេសដើម្បី បង្កើតជា ស៊ូណាមីប្រជាពលរដ្ឋ ដៃកាន់ផ្កាឈូកនិងកាម៉េរាថតរូបថែម ទាំងមាន ពាក់អាវយឺតរូបផ្កាឈូកប្លែកៗ ពិសេសផ្ទាល់ខ្លួន ទៀតផង ។ អង្គការការពារសិទ្ធិលំនៅថាន ដែលបង្កើត ឡើងដោយ អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ១២ និង អ្នកស្រុកបឹងកក់បានអនុវត្តសកម្មភាពនេះដោយជោគជ័យ ។ បើការមិនគោរព រដ្ឋ បែប ស៊ីវិល ទូទាំង ប្រទេស មានទ្រង់ទ្រាយធំធេងឡើងៗ ដូចជា ការមិនចូលរួមបោះឆ្នោត ការ បរិហារនយោបាយូបនីយ កម្មនៃតុលាការ អនិទណ្ឌភាពនៃអ្នកដឹកនាំ ការមិនអនុវត្តច្បាប់ ការរំលោភអំណាច ប្រើ ប្រាស់កងទ័ព ប៉ូលីស និងកងអង្គរក្សពី៥ ទៅ៧ ពាន់នាក់ សំរាប់ បង្ក្រាបបាតុករ ,,, នោះជោគជ័យ ជាបញ្ចប់ នឹងរិតតែ ខិតជិត មកដល់ ។ រូបភាព នៃការ

ប្រយុទ្ធរបស់កុមារាកុមារីជាបុត្រធីតនៅស្ត្រីបឹងកកដែលជាប់ក្នុងពន្ធនាគារព្រៃសរ ដៃកាន់ផ្កាឈូក គឺជានិមិត្តរូបនៃការប្រយុទ្ធគ្មាន ទោសគ្មានពៃរ៍  ជាអនាមិក និង អហឹង្សា  ដើម្បីសិទ្ធិមនុស្ស ឯករាជ្យជាតិ និងសេរីភាព។  បដិវត្តន៏ផ្កាឈូក មើលឃើញ កុមារា កុមារី ដែលយំរហាម ថាជា និមិត្តរូប និងជាគោលដៅជាក់ស្តែងនៃការរំដោះ។ បក្សប្រជាជនកំពុង ភ័យចលាចលជ្រួលច្របល់ ខ្លាំង ហើយបែរជាចោទអ្នកតវ៉ាធ្វើបាតុកម្មក្នុងស្រុកឆ្លូង ខេត្តក្រចេះ ថាជា អបគមជន ដើម្បីគេអាច ធ្វើការបង្រ្កាប យ៉ាងធ្ងន់ធ្ងរតាមផ្លូវច្បាប់ទៅ លើពលរដ្ឋ។  លោកម៉មសុណង់ដូ ប្រធានសមាគមអ្នកប្រជាធិបតេយ្យ ក៏បាន ទទួលការគំរាម កំហែង តាមខ្យល់ ពីហ៊ុនសែន ថានឹងចាប់គាត់ដាក់គុកដែរ។

នៅក្នុងការបណ្តេញ ប្រជាជនបឹងកក់ បូរីកីឡា ដីក្រហម ស្នួល ឆ្លូង( ក្រចេះ)     គេសង្កេតឃើញមាន និទណ្ឌភាពជានិច្ចនិរន្តទៅលើឧក្រិដ្ឋជនដោយពុំគិតគូរដោះស្រាយពីការខូចប្រយោជន៏នៃប្រជាពលរដ្ឋទេ។ តើគេនឹងអាចដឹងការ ពិតលើឃាតកម្ម ដោយកាំភ្លើងនៅខេត្តកោះកុង លើ លោកឈុតវុទ្ធី ដែល ជាប្រធានអង្គការការពារធនធានធម្មជាតិ ឬទេ? ចុះការពិត លើ មរណភាពនៃ នាង ហេងចន្ថា អាយុ១៤ឆ្នាំ នៅក្នុងការបង្រ្កាបបាតុករនៅ ភូមិប្រមា ឃុំកំពង់ដំរី ស្រុខឆ្លូង ខេត្តក្រចេះ? ប៊ុនវដ្ឋា បានរត់ភៀសខ្លួនពួនជាសំងាត់ ដើម្បីគេចចេញពីរន្ទះហ៊ុនសែនដែលចោទគាត់ថាជាអបគមជន។  លោកប៊ុនឈនជាឪពុក និង លោកសុខតុង កំពុងម្រឈមមុខការចោទប្រកាន់ពីតុលាការក្រោមអំណាចហ៊ុនសែន ដែលបង្ខំឱ្យគេទាំង២ឆ្លើយដាក់លោក សួណង់ដូ ប្រធានសមាគមអ្នកប្រជាធិបតេយ្យ ថាជាអ្នកទទួលខុសត្រូវក្នុងការបង្កើតអប្បគមន៏សិប្បនិមិត្តនេះ ។  ប្រជាជាតិ ខ្មែរ ត្រូវតែបំផុសសំពាធក្នុងស្រុក និងក្រៅស្រុក ឱ្យខ្លាំងក្លា លើអំណាចផ្តាច់ការបក្សប្រជាជនហ៊ុនសែន និលើប្រទេសយួន។ គឺដោយសារការ តវ៉ាប្រឆាំងគ្រប់ទិទីនៃ អង្គការ ក្រៅ រដ្ឋាភិបាល ក្នុងស្រុកនិងអន្តរជាតិ  ដែលបានផ្សាយប្រាប់ ឱ្យសហគមន៏អន្តរជាតិដឹងឮ នេះហើយ ទើបបក្សប្រជាជន សំរេចចិត្ត ព្យួរច្បាប់ ប្រឆាំងអង្គការក្រៅរដ្ឋភិបាលទុកមួយរយ:សិន។ ប្រទេសផ្តល់ជំនួយ នានាក៏បាន ផ្អាកជំនួយមួយរយ:សិនដែរ។  ក្រោមការក្បៀបសង្កត់ជាតិនិងអន្តរជាតិ ក្រុមការពារសិទ្ធិលំនៅថានបានទទួលជោគជ័យក្នុងការទាំទារឱ្យដោះលែង អ្នក ភូមិ១៥នាក់ដែល រដ្ឋអំណាចបាន បណ្តេញចេញ ពីទឹកដីរបស់ខ្លួន ហើយចាប់ដាក់គុកព្រៃសរ ក្នុងនោះមានស្ត្រីបឹងកក់១៣នាក់ ផងដែរ។ សកម្មភាពរួមនេះ កំពុងតែហុច ផ្កាផ្លែមកឱ្យហើយ។ ប្រជាពលរដ្ឋត្រូវតែបន្តដើរតាម ផ្លូវនេះទៀត ដេីម្បីធ្វើឱ្យមាន ការ ចាប់ចង និងកាត់ទោស ឃាត់រក្សា ទ្រព្យសម្បត្តិទុក មិនឱ្យប្រើប្រាស់ ហាមឃាត់ អ្នកដឹក នាំខ្មែរមិនឱ្យធ្វើដំណើរទៅប្រទេសសេរីនានា មាន ប្រទេស អូស្រ្តាលី កាណាដា សហរដ្ឋអាមេរិក និង ប្រទេសអឺរ៉ុប ជាដើម។

***<u>បងប្អូនរួមជាតិជាទីគោរព!</u>***

ពលរដ្ឋខ្មែរទូទាំងពិភពលោកខ្លះ បានចូលរួមរួចមកហើយ ទោះជាដោយផ្ទាល់ក្តី ជាប្រយោលក្តី ក្នុងការធ្វើបដិវត្តន៏ផ្កាឈូក ទាំង អស់គ្នា ដើម្បីដោះស្រាយបញ្ហា សង្គមកិច្ច ផ្ទាល់ខ្លួន ជាបន្ទាន់របស់ជនរួមជាតិយើងផង មានការបណ្តេញចេញពិលំនៅថាន ដោយ កំលាំង បញ្ហាអយុត្តិធមិ កិរិតបៀវត្សរ៏ទាប  និងបញ្ហាជាប្រយោជន៏ជាតិផង ដូចជាឯករាជកម្ពុជា អំពើផ្តាច់ការការកិរិតបន្ថយ សេរីភាព  ការចាប់ដាក់គុកតាមអំណាចផ្តាច់ការ ការកាប់បំផ្លាញព្រៃឈើ ការកាត់ដែនសមុទ្រនិងដែនដីមានភូមិខ្មែរ ទៅឱ្យយួន ជាដើម។ មានតែ បដិវត្តន៏ ផ្កាឈូកនេះ ទេដែលអាចឆ្លើយតបចំៗនិងជាទូទៅ ដើម្បីរំដោះ ប្រទស កម្ពុជា និងពលរដ្ឋខ្មែរបាន។    យើងត្រូវយកគំរូដំសែនវិជ្ជមាននៃអង្គការកាពារសិទ្ធិលំនៅថាន និងនិងបុត្រធីតានៃស្ត្រីម្តាយអ្នកភូមិបឹងកក់ដែលជាប់ពន្ធនាគារ។ យើងត្រូវបន្តជួយទៀត ដូចដែលអង្គការក្រៅរដ្ឋាភិបាល១៥ កំពុងធ្វើមានអង្គការលីកាដូជាដើម ដែលសុំឱ្យរដ្ឋការក្រុងភ្នំពេញ ដឹកនាំសេវាសុរិយោដីមកវាស់ វែងនិងចែកចាយដី១២,៤៤ហត ឱ្យអ្នកស្រុកបឹងកក់។ គឺជានិមិត្តរូប

នៃការគ្មានទោសគ្មានពៃរ៍ នៃសេចក្តីស្នេហា នៃភាពអនាមិក នៃក្តីសង្ឃឹម និងសាមគ្គីធម៌ របស់ប្រជាជាតិយើង នៅក្នុងការ ប្រយុទ្ធ ដើម្បីសេរីភាព និងឯករាជ្យនៃមាតុប្រទេសរបស់ខ្លួន។ គឺជាសាមគ្គីភាព សហភាព នៃការ បង្រួបបង្រួមគ្នាក្នុង សភាពប្លែកៗពីគ្នា ។


អ៊ូ ចល

សមាជិកស្ថាបនិក ជិវត្តន៍ផ្កាឈូក

បណ្ឌិតទស្សនវិជ្ជា សាកលវិទ្យាលយស័របោន ប៉ារីស

(DEA de Philosophie- Sorbonne  Paris)

បណ្ឌិតពត៌មានវិទ្យាឯកសារ  សាកលវិទ្យាល័យលីយ៉ុង១ និង អិនស៊ីប

(DESS Informatique Documentaire- Lyon I & ENSSIB)


****************************